# សៀវភៅគតិលោក
# ភាគ ទី៤



សុត្តន្តប្រីជា ឥន្ទ

១៨៥៩ - ១៩២៤

ChanBoKeo.COM

## ពណ៌នាពីសេចក្ដីឆោតនិងនិទានពីតាចាស់ម្នាក់

រឿងនិទានមនុស្សឆោតនេះ នៅមានច្រើនណាស់
យើងពុំឈ្នះនឹងនាំមកពណ៌នាឲ្យអស់ គឺសំដែងទុកតែប៉ុណ្ណោះ
ល្មមជាបែបបានជាគិតលោកហើយ ចូរឯងចូរចិត្តចុះ សព្វ
តម្រាឆោតទាំងប៉ុន្មានៗនេះ សឹងចុះក្នុងកិរិយាឥតសតិសម្ប
ជញ្ញះ១នេះឯង បើមានសតិសម្បជញ្ញះ យ៉ាងស្ដេចពានរបរម
ពោធិសត្វ កាលចៅក្រពើរទៅដេកក្រាបលើថ្មបញ្ឆោតឲ្យ
មហាពានរលោតទៅលើខ្លួន ដើម្បីនឹងចាប់យករូបពោធិសត្វ
ៗមិនឆោតតាមគំនិតខ្លួន ហើយពោធិសត្វបញ្ឆោតក្រពើរ
នោះបានវិញ ។

មួយទៀត និទានមាន់ចែចែកខ្លួនរួចអំពីសំពោចធ្វើឲ្យសំពោច
ភិតភ័យរត់ទៅវិញ រឿងអស់នេះអ្នួរឯងចូលចិត្តចុះ ។

កូនសិស្សតបគ្រូវិញថា:

សូមទានរឿងមនុស្សឆោតខ្លៅអស់នេះសឹងមានតែក្នុងកាល
យើងឥឡូវនេះទេឬក្នុងកាលពុទ្ធុប្បាទដែលព្រះសម្មាសម្ពុទ្ធ
ទ្រង់ព្រះធរមាននៅឡើងនោះមានមនុស្សឆោតខ្លៅដូចយ៉ាង
យើងឥឡូវនេះដែរទាន ។



គ្រូតបថា: ឯមនុស្សឆោតខ្លៅនេះ មិនមែនមានតែក្នុងកាល
ឥឡូវនេះទេ ទោះនៅក្នុងកាលពុទ្ធុប្បាទនោះក៏មានមនុស្ស
ឆោតដូច្នេះដែរ ឯងមិនទាន់ចូលចិត្តទេឬ គឺកាលព្រះពុទ្ធជា
ម្ចាស់បានត្រាស់នោះមានគ្រូធំ៦នាក់ មានគ្រូឈ្មោះបូរណក
ស្សបៈជាដើមឯពួកគ្រូអស់នោះសឹងកាន់លទ្ធិផ្សេងៗ មាន
ប្រព្រឹត្តកាយអាក្រាតជាដើម បាននាមហៅថា អចេលកបុ
គ្គល ប្រតិបត្តិផ្លូវអត្តកិលមថានុយោគផ្សេងៗ ទាំងមានមនុ
ស្សទាំងឡាយចូលចិត្តជឿរាប់អាន ប្រព្រឹត្តតាមជាងរយជា
ងពាន់នាក់ ប្រតិបត្តិកាន់យកទុកជាសាសនាតៗមក នៅដ
រាបដល់ឥឡូវនេះ ។

មួយទៀត មានមនុស្សពួកខ្លះប្រតិបត្តិខាងផ្លូវព្រហ្ម
ញ្ញសាសនា មានកាន់ពិធីបូជាយញ្ញ បូជាគ្រោះ បង្កក់ប្រសិទ្ធិ
សែនពែជាដើម ។

មនុស្សទាំងឡាយឯណា កើតនៅក្នុងសំណាក់គ្រូណា
អ្នកនោះ ក៏កាន់លទ្ធិកាន់សាសនារបស់គ្រូនោះទាំងអស់ ដើ
ម្បីនឹងមានសតិសម្បជញ្ញះពិចារណាមើលខុសត្រូវឲ្យសម
ហេតុសមផលនោះពុំមាន ឃើញតែមាតាបិតា ក្នុងវង្ស-

....ត្រកូលខ្លួនប្រតិបត្តិយ៉ាងនោះឯងទោះមានលោកអ្នកប្រាជ្ញណា ទៅនិយាយដាស់តឿនបង្ហាញផ្លូវត្រង់ ឲ្យលះបង់លទ្ធិនោះចោល ក៏មិនព្រមលះចោល ក៏មិនព្រមលះចោល នៅប្រកាន់តម្រាមាតាបិតាគ្រូបាអាចរ្យខ្លួនថាតម្រាបុរាណសុទ្ធសឹងតែត្រូវទាំងអស់ ។

មួយទៀត មនុស្សឯណាកើតក្នុងកាលវិបត្តិ គឺកើតក្នុងសុញ្ញកប្ប១ កើតក្នុងទេសវិបត្តិ គឺប្រទេសនោះពុំមានសាសនាត្រឹមត្រូវ១ កើតក្នុងកុលវិបត្តិ គឺកើតក្នុងវង្សត្រកូលមិច្ឆាទិដ្ឋិ មានគោត្រត្រកូលព្រានព្រៃជាដើម១ មនុស្សនុះគង់លុះនៅកាន់សទ្ធិខុស សទ្ធិឆោតមិនលែង ។

ឯងចូលចិត្តចុះ មនុស្សឆោតល្ងង់នេះមិននៅក្នុងកាលឥឡូវនេះទេ ទោះមនុស្សកើតមុនពុទ្ធុប្បាទកើតក្នុងវាងព្រះពុទ្ធុប្បាទនៅក្តី ឬកើតជាន់ក្រោយព្រះពុទ្ធុប្បាទក្តី សឹងមានឆោតល្ងង់តាមពួកៗដូចគ្នា ។

មួយទៀត ក្តីឆោតនេះបើនិយាយដោយយ៉ាងល្អិតនោះ សឹងមាននៅគ្រប់តួមនុស្សទាំងអស់ទូទៅ វៀរវែតែលោកអ្នក បានលុះផ្លូវអរិយបុគ្គលទាំង ៤ ចំពួកមានព្រះសម្មាសម្ពុទ្ធជាប្រធាន



នោះទើបលោកលោតកន្លងផុតក្តីឆោតនេះបាន ព្រោះលោកមានកែវឆ្លុះគឺលោកុត្តរបញ្ញា មើលឃើញពន្លឺព្រះនិព្វានច្បាស់ហើយ តែឯមនុស្សយើងបុថុជ្ជននៅធ្ងន់ដោយរាគៈ ទោសៈ មោហៈ លោភៈ ជាដើមនេះ សឹងធ្លាក់ទៅក្នុងក្តីឆោតឯណានីមួយមិនលែងឡើយ ព្រោះក្តីឆោតនេះ កើតដោយអរម្មណ៍លោកិយផ្សេងៗ ដូចបុគ្គលប្រុសស្រីខ្លះ វង្វេងទៅដោយកិលេសកាមរោលរាលយ៉ាងខ្លាំងមិនទទួលញ៉មខ្លួនចាំបាច់ជរា នៅសំគាល់ខ្លួនថាជាកំឡោះ ជាក្រមុំ តាំងស្វែងរកផ្លូវតាមបបោសអង្អែលរូប សំឡេង ខ្លិន រស សម្ផស្ស ជារបស់កាមគុណ កើតក្តីត្រេកត្រអាល ប្រាសចាកក្តីអៀនខ្មាស មិនដឹងខ្លួនថាចាស់ជរាចចេសលើសសង្ខារ ។ ដូចនិទានតាចាស់ម្នាក់ឈ្មោះ តាអ៊ុមយោគី នៅស្រុកព្រះតំបង តាយោគីនោះឯងវង្វេងស្រឡាញ់ក្មេងក្រមុំ គ្រាកាលណោះ មានមេស្រីអ្នកលេងវាដឹងថា តាអ៊ុមយោគីចង់ស៊ីផ្លែទន្លាប់ស្រស់ទើបវាយកផ្លែទន្លាប់ស្រស់របស់វា ទៅប្រលោមឲ្យអ៊ុមអង្អែលលេងខ្លះ ដើម្បីយកមាសប្រាក់ទ្រព្យសម្បត្តិរបស់តាអ៊ុមៗ តាំងតែឆោតវង្វេងយកទ្រព្យធនរបស់ខ្លួនលើកឲ្យទៅមេអ្នកលេងទាល់តែអស់ ដោយហោច

ទៅតែសំពត់សប្ធ គ្រឿងថង់យាម កន្ទេលខ្នើយដែលបានមកអំពីកិច្ច ដែលខ្លួនទៅធ្វើយោគីផុតខ្លោចឲ្យគេនោះ ក៏បានដៃមេអ្នកលេងទាំងអស់ទាល់តែតាអ៊ុំធ្លាក់ខ្លួនជាអ្នកក្រ ៗ

រឿងមនុស្សចាស់ជរា លុះផ្លូវកាមរាគរោលខ្លាំងហើយ សឹងជាផ្លូវឲ្យមេស្រីអ្នកលេងដើរចូលមកបញ្ឆោតបានទាំងអស់ សឹងលុះក្ដីបរាមុខក្នុងលោកយើងនេះ ដូចបងបាលីមានក្នុងគម្ពីរលោកនីកិថា៖

អតិមហល្លកោ ចោសោ
អនេសិ តិម្ពរុថនី
តស្សាវសានុសន្ធតិ
តំ បរាភវតោ មុខំ។

អធិប្បាយជាពាក្យឃ្លោងថា ចាស់ចើកបានជួននួនក្រមុំដោះក្បំពកប៉ុនផ្លែទន្លាប់ សែនស្រឡាញ់ពេញចិត្តប្រព្រឹត្តជាប់ របស់ក៏ផ្គាប់វាទាំងអស់ ៗ វាអើយកាលណានឹងឲ្យភ្លាម ស៊ូព្យាយាមអផ្អែលទន្លាប់ស្រស់ ស៊ីពុំបានក៏ស៊ូហិតតែរស ការទាំងអស់ជាហេតុអន្តរធាន ៗ

**ចប់ខាងសេចក្តីឃាតមនុស្សប្រុសដោយសង្ខេប។**



# និទានពីយាយចាស់ល្មោភកាមគុណ

ឯខាងមនុស្សស្រីចាស់ចើកវិញនោះ បានដូចរឿងយាយចាស់ម្នាក់ឈ្មោះសំ នៅស្រុកព្រះតំបងយាយនោះអាយុ៧០ ផ្លាយរូបជរា គឺធ្មេញបាក់អស់សក់ស្កូវ ខ្នងកោង ដើរកាន់ឈើច្រត់ ៗ

កាលណោះ មានបុរសម្នាក់ឈ្មោះចៅម៉ៅទៅសុំយាយសំជាម្ដាយធម៌ យាយសំក៏ស្រឡាញ់ចៅម៉ៅជាកូនធម៌ លុះនៅយូរមកយាយសំកើតភ្លើងកាមរាគរោលខ្លាំង តាំងស្រឡាញ់ចៅម៉ៅដោយការផ្លូវលោកិយ ស៊ូផ្គាប់ផ្គុនចៅម៉ៅ សំដែងមាយាស្ត្រីញាំងចៅម៉ៅឲ្យត្រេកក្នុងការលោកិយផ្សេងៗ ឯចៅម៉ៅដឹងខ្លួនក៏រត់ចោលយាយសំៗ ក៏ស៊ូដើរតាមរកចៅម៉ៅ ដូចនិទានរឿងនាងមេរីដើរតាមរកព្រះនាគសែននោះឯង ៗ

ឯកាមរាគ១នេះមែន បើមាននៅលើរូបយាយចាស់ឯណាហើយ ក៏អាចធ្វើឲ្យយាយចាស់នោះវង្វេងបាត់ក្ដីអៀនខ្មាសកូនកូនចៅខ្លួននឹងអ្នកដទៃនានា អាចកាត់ក្ដីស្រឡាញ់កូនចៅបានហើយទទួលពាក្យបញ្ឆោរអ្នកដទៃគឺគាប់ចិត្តនឹងពាក្យហៅនាងឬអ្នក បើនរណាហៅយាយយ៉ាងនេះពុំគាប់ចិត្តឡើយ មួយ......

.....ទៀតបើសក់ក្បាល់ស្កូវ ក៏រែកកក្រមួនឬប្រេងលាយខ្ទុកឲ្យបានសក់ខ្មៅមួយគ្រាៗឬរួចដល់ជរាខ្វងកោង ក៏ខំដើរអើតដើរងើត ចោលឈើច្រត់មិនចាំកាន់ក៏បានមួយទៀត កាមរាគនេះមានកម្លាំងអាចកាត់កូនចៅក៏បាន អាចហ៊ានសម្លាប់កូនចៅខ្លួនបាន ដូចនិទានយាយព្រាហ្មណីជាមាតានៃពោធិសត្វនោះឯងរឿងនោះមានសេចក្ដីថា កាលណោះ ព្រះពោធិសត្វទៅកើតជាកូននាងព្រាហ្មណី បិតាដល់នូវមរណកាល ពោធិសត្វចំរើនធំឡើង បានរៀនចេះដឹងក្បួនត្រៃភេទចប់ ឡើង ទីជាអាចារ្យទិសាបាមោក្ខ មានកូនសិស្សទៅរៀនវិជ្ជានោះជាច្រើន ឬមាតានៃពោធិសត្វនោះចំរើនអាយុដល់៨០ឆ្នាំប្លាយ រូបកាយក៏ទុព្វលភាពចាស់ជរាសាច់ស្វិតយុរយារ នេត្រាមើលយល់ព្រិលៗ គ្រាកាលនោះមានមាណពកំឡោះម្នាក់មានរូបសោភា ចូលទៅសូមរៀនវិជ្ជាសិល្បសាស្ត្រនឹងបរមពោធិសត្វៗ បានបង្ហាត់បង្រៀនវិជ្ជាអស់៣ឆ្នាំ ចៅមាណពនោះរៀនចេះចប់ហើយ ក៏លាពោធិសត្វជាគ្រូវិលទៅស្រុកអាត្មា ដល់ហើយក៏សំដែងវិជ្ជានោះប្រាប់មាតាបិតារបស់ខ្លួនសព្វប្រការ ឯមាតានៃចៅមាណពនោះសួរថា សិល្បសាស្ត្រទាំងពួងនេះចៅរៀនចប់ហើយ ចុះឯវិជ្ជាមាយាស្ត្រីនោះតើ



កូនឯងរៀនចេះខ្លះហើយឬ?ៗ

ចៅមាណពជំរាបម្ដាយថា នៅពុំទាន់បានរៀនទេទើបមាតាបញ្ជូនមាណពនោះ ឲ្យវិលទៅរៀនវិជ្ជាមាយាស្ត្រីនឹងពោធិសត្វវិញ និយាយសូមរៀនវិជ្ជាមាយាស្ត្រីឯពោធិសត្វក៏ប្រាប់ថា វិជ្ជាមាយាស្ត្រីនោះគឺមាតាយើងគាត់ចេះ បើដូច្នេះចៅឯងចូលទៅរៀនតពីមាតាយើងឯក្នុងផ្ទះចុះៗ

ចៅមាណពក៏ចូលទៅប្រតិបត្តិយាយចាស់សូមរៀនមាយាស្ត្រីតាមក្ដីប្រាថ្នា ឯមាតាពោធិសត្វបានឃើញចៅមាណពរូបល្អមកប្រតិបត្តិខ្លួន ក៏កើតភ្លើងកាមរាគរោលប្រាណ មានចិត្តស្នេហាស្រឡាញ់ចៅមាណពប្រារព្វចង់បានជាប្ដី ទើបនិយាយប្រស្រ័យលួងលោមដោយផ្លូវលោកិយ ប្រើកិរិយាស្ត្រីនោះផ្សេងៗហើយថាខ្ញុំឯងស្រឡាញ់អ្នកឯងណាស់ ចូរអ្នកឯងទទួលផ្លូវមេត្រីជាប្ដីខ្ញុំនេះចុះៗ

ឯចៅមាណពនោះក៏ឆ្លើយថា ការនេះខ្ញុំពុំហ៊ានទេ ព្រោះលោកគ្រូជាកូនលោកយាយ លោកក៏ជាអាចារ្យលើខ្ញុំៗតែងគោរពប្រតិបត្តិលោក ដូចលោកយាយឃើញស្រាប់ពុំគួរខ្ញុំបានជាសិស្សទៅប្រព្រឹត្តកន្លងយ៉ាងនេះសោះ យាយចាស់......

......នោះក៏តបវិញថា ការនោះមិនអីទេ លែងតែអ្នកឯងព្រមចិត្តព្រមគំនិតនឹងយើងនេះចុះ ឯត្រង់រូបកូនយើងនេះយើងនឹងគិតសម្លាប់បង់ កុំឲ្យមានក្តីរង្កៀសដល់អ្នកឯងឡើយ។

ចៅមាណពក៏ឆ្លើយថា បើលោកយាយហ៊ានសម្លាប់កូនដូច្នោះ ខ្ញុំបានក៏ព្រមតាម ថាហើយចៅមាណពក៏ស្ទុះចេញមកខាងក្រៅ ហើយនាំពាក្យនោះទៅជំរាបពោធិសត្វៗក៏និយាយថា បើមាតាយើងគាត់គិតសម្លាប់យើងដូច្នោះ ចូរបាឯងទៅសួរគាត់វិញថា គាត់ប្រារព្ធនឹងសម្លាប់នោះ តើសម្លាប់ក្នុងថ្ងៃណា ក្នុងពេលណា សម្លាប់ដោយឧបាយដូចម្តេច។

ឯចៅមាណពទទួលពាក្យពោធិសត្វហើយ ក៏ចូលក្នុងផ្ទះ និយាយសាកសួរយាយនោះ តាមពាក្យនៃពោធិសត្វគ្រប់ប្រការ ឯយាយចាស់ក៏ប្រាប់ថា យើងនឹងសម្លាប់កូនយើងក្នុងវេលារាត្រីយប់នេះ គឺយើងចាំមើលកូនយើងដេកលក់កាលណា យើងនឹងកាន់ដាវដ៏មុត លបចូលទៅប្រហារឲ្យដាច់កមួយរំពេចក្នុងកាលនោះ ការអស់នេះ ចូរអ្នកឯងកុំនិយាយចេញទៅឲ្យអ្នកដទៃក្រៅគេដឹងឮឡើយ មែនណាបើការយើងពីរនាក់នឹងបាននៅជាមួយគ្នាជាប្តីប្រពន្ធតទៅ។



ឯចៅមាណពក៏ធ្វើជាទទួលពាក្យហើយក៏ក្រោកដើរចេញមកខាងក្រៅ នាំសេចក្តីនោះទៅប្រាប់ពោធិសត្វជាគ្រូសព្វប្រការ។

ពោធិសត្វបានស្តាប់ហើយ ក៏កំណត់ទុកក្នុងចិត្តលុះដល់វេលារាត្រី ទើបកាត់ដើមចេកមួយកំណាត់ប្រមាណ៤ហត្ថ នាំយកទៅដាក់ផ្តេកនៅទីដំណេកអាត្មា ហើយយកសំពត់គ្របពីខាងលើដើមចេកនោះធ្វើការដូចជាមនុស្សដេកលក់ ស្រេចហើយពោធិសត្វនាំចៅមាណពជាកូនសិស្សនៅរង់ចាំមើលកិរិយានៃមាតានោះ។

ឯយាយចាស់នោះលុះដល់យប់ស្ងាត់ក៏រៀបអាត្មាកាន់ដាវដើរលបចូលទៅក្នុងដំណេក នៃពោធិសត្វដល់ហើយលូកដៃស្ទាបទៅប៉ះលើសំពត់ដណ្តប់ ក៏កំណត់ថា នេះខាងក្បាល នេះខាងជើងយាយចាស់លើកដាវដាឡើងទាំងកាប់ដោយគិតថាប្រហារជីវិតឲ្យដាច់កក្នុងកាលនោះ យាយចាស់ប្រឹងលើកដាវហើយប្រហារចុះ ដោយកម្លាំងប្រឹងនោះខ្លាំង និមិត្រតែដាវធ្លាក់ដល់ដើមចេកកាលណា យាយចាស់ក៏ដួលចុះដល់ដាច់ខ្យល់ដល់មរណកាល ក្នុងកាលនោះឯង។

ពោធិសត្វនឹងចៅមាណពលបមើលកិរិយាដឹងថាយាយនោះដួលស្លាប់ដូច្នោះ ក៏កើតធម្មសង្វេគហើយចាត់ចែងក្តារមឈូសដាក់សព នាំទៅធ្វើឈាបនកិច្ចតាមប្រពៃណីជាតិជាព្រាហ្មណ៍ ។

រឿងនិទាននេះមានសេចក្តីពិស្តារនៅក្នុងគម្ពីរដីកាព្រះធម្មចក្កងណោះ យើងទាញយកមកសាធក:ទុកក្នុងតម្រាគតិលោកនេះ ដើម្បីឲ្យឃើញក្តីឆោតរបស់បុរសស្ត្រីក្នុងលោកិយដែលមានសន្តានចិត្តប្រព្រឹត្តឆោតទៅតាមអំណាចភ្លើងកាមរាគទោល ដល់នូវក្តីវិនាសមានសភាពដូចសំដែងមកនេះឯង ចូរឯងចូលចិត្តចុះ ។

កូនសិស្សតបថា ករុណាលោកគ្រូទាញនិទានបុគ្គលឆោតលុះដោយអំណាចភ្លើងកាមនោះ ខ្ញុំករុណាស្តាប់បានយកជាគតិលោកហើយ មួយទៀតបុគ្គលឆោតល្ងង់ជឿគេផ្តាសៗនោះ គឺអាស្រ័យឥតសតិឥតបញ្ញានិងពិចារណាឲ្យយល់ចុងយល់ដើមកើតឆោតដោយភ្លើងកាមរាគទោលរឹតបិទសតិបញ្ញា ដូចនិទានយាយព្រាហ្មន៍ដែលលោកគ្រូសំដែងមកនេះ ករុណាទានសេចក្តីឆោតល្ងង់នេះមានកើតដោយហេតុអ្វីខ្លះដែរទាន ។

គ្រូតបថា ក្តីឆោតល្ងង់ដោយហេតុឯទៀតក្រៅអំពីភ្លើង



កាមរាគនោះ សឹងមានជាច្រើនណាស់ពុំឈ្នះនឹងពណ៌នា ឯងចូលចិត្តចុះ មានខ្លះឆោតដោយខ្លាចរូបកាយគឺសង្ខារខ្លួនឯង ដូចបុគ្គលគិតខុសប្រមាណខុស គឺអ្នកខ្លះឥតកូនឥតចៅកើតខ្លាចថាដល់អាត្មាស្លាប់ទៅ ពុំមាននរណាកាន់ឆ្អឹង ម្ល៉ោះហើយស្វែងសុំកូនចៅគេមកចិញ្ចឹមទុក ដើម្បីឲ្យកូននោះកាន់ឆ្អឹងខ្លួន ចូនពុំសមតាមសេចក្តីប្រាថ្នា ក៏កើតវិប្បដិសារីសេចក្តីក្តៅក្រហាយជាក្រោយប្រព្រឹត្តទៅផ្សេងៗយ៉ាងនេះក៏មាន ។

មានអ្នកខ្លះខ្លាចភ្លើងផ្តាំគេថា ដល់ខ្លួនស្លាប់ទៅកុំឲ្យគេដុតរូប ខ្លាចក្រែងរលាកភ្លើង យ៉ាងនេះក៏មាន មានអ្នកខ្លះគិតខ្លាចទាកជន្លេនផ្តាំគេថា ដល់ខ្លួនស្លាប់ទៅកុំឲ្យគេយករូបទៅកប់ក្នុងដី ខ្លាចជន្លេនវារុក ដូច្នេះក៏មាន មានអ្នកខ្លះខ្លាចខ្មោចផ្តាំគេថា ដល់ខ្លួនស្លាប់ទៅកុំឲ្យយករូបទៅកប់ទុកក្នុងព្រៃស្មសានស្ថានស្ងាត់ជិតនឹងខ្មោចគេ ក្រែងខ្មោចគេវាលង យ៉ាងនេះក៏មាន មានអ្នកខ្លះឆ្កួតយស កាលខ្លួននៅរស់ពុំបរិច្ចាគទ្រព្យសម្បត្តិធ្វើបុណ្យឲ្យទាន សន្សំទ្រព្យទុក ផ្តាំគេថាដល់ខ្លួនស្លាប់ទៅឲ្យធ្វើក្តារបិទមាស ឲ្យធ្វើកោដ្ឋដាក់ដំកើងខ្មោចខ្លួន ដើម្បីអួតលោកិយ យ៉ាងនេះក៏មាន ។

មានអ្នកខ្លះស្វែងរកទីដីល្អមានហុងស៊ុយបញ្ចុះធាតុម្តាយអាពុ
កដើម្បីរកស៊ីធូរសុខសប្បាយ យ៉ាងនេះក៏មាន អ្នកខ្លះកាន់តម្រា
សែយំមានក្បួនរើសថ្ងៃល្អ យាមល្អ ថ្ងៃកាឡកណ្ណី ថ្ងៃខ្មោចស៊ី
មនុស្ស ថ្ងៃលិច ថ្ងៃអណ្តែត ថ្ងៃជីពចរ មើលទិសដង្ហើមរស់
ដង្ហើមស្លាប់យ៉ាងនេះជាដើមក៏មាន មានអ្នកខ្លះកាន់រើសថ្ងៃចន្ទ
ជាថ្ងៃទទួលយកប្រាក់ដាក់ថង់ គឺថាជាប្រាក់មានស្រីសួស្តីមង្គល
ទោះបីអ្នកឯណាដែលជំពាក់ខ្លួន ឬតួទាសាទាសីនឹងចេញនាំប្រា
ក់ទៅជូន តែមិនត្រូវត្រង់ថ្ងៃចន្ទ១ ហើយក៏ពុំទទួលយកនៅរង់
ចាំដល់ថ្ងៃចន្ទទើបទទួលយកប្រាក់នោះ អ្នកកាន់ក្បួនថ្ងៃចន្ទទទួ
លប្រាក់ថាជាប្រាក់ត្រជាក់ក៏មាន ចួនណាប្រែជាកើតក្តីក្តៅក្រ
ហាយជាក្រោយវិញក៏មាន ដូចនិទានលោកព្រះចំរើនពលទិព្យ
នៅស្រុកព្រះតំបង លោកនោះជាអ្នកកាន់ក្បួនថ្ងៃចន្ទ គ្រាកាល
នោះ លោកមានតួទាសាម្នាក់ឈ្មោះអាម៉ូតៗ នៅនឹងលោកជាថ្លៃ
ប្រាក់មួយរយបាតសៀម លុះនៅយូរមក អាម៉ូតទៅចូលលួច
ប្រាក់ប្លមជាមួយនឹងម្តាយអាពុកវា លោកព្រះចំរើនពលទិព្យជា
ម្ចាស់ប្រាក់ ក៏ពុំដឹងជាអាម៉ូតប្រព្រឹត្តការខុសជាប់ដោយទោស
ហ្លួង លុះនៅយូរបន្តិចមក អាម៉ូតចង់ចេញទើបវាទៅរកប្រាក់



អ្នកមានឈ្មោះៗ ក៏ព្រមនឹងលោះតួអាម៉ូតៗ ក៏នាំអ្នកម្ចាស់ថ្មីយក
ប្រាក់១០០ បាទសៀមទៅជូនលោកព្រះចំរើនពលទិព្យនោះ
ចួនលោះនៅក្នុងថ្ងៃសៅរ៍ ឯលោកព្រះចំរើនពលទិព្យប្រកាន់
តម្រា ទទួលប្រាក់ថ្ងៃចន្ទទើបមិនទទួល ហើយនិយាយណាត់
សញ្ញាថាបង្អង់ដល់ថ្ងៃចន្ទខានស្អែកសិនចុះ សិមយកប្រាក់មក
បង់សិមបើកឲ្យៗ ឯអ្នកម្ចាស់ថ្មីឮថាលោកព្រះចំរើនពលទិព្យ
ពុំទទួលប្រាក់ដូច្នោះ ក៏នាំយកប្រាក់នោះវិលមកផ្ទះវិញនៅរង
ចាំដល់ថ្ងៃចន្ទនឹងទៅបង់លោះតួអាម៉ូតនោះឯងៗ លុះដល់ថ្ងៃ
អាទិត្យពួកអ្នករាជការចាប់មេសៅ ចៅប៉ែនជាម្តាយអាពុកអា
ម៉ូតព្រមទាំងតួអាម៉ូតជាកូន មួយអន្លើនឹងគ្រូដែលបោះប្រាក់
ប្លមជាទោសហ្លួង នាំទៅជូនលោកចៅពញាធរឃុមចៅហា
យស្រុក លោកក៏ឲ្យចាប់អាពុកអ្នកទោសនោះដាក់គុកតាម
ទោសានុទោស ឯតួអាម៉ូតក៏ត្រូវក្តីជាប់ជាទោសហ្លួងៗ

ឯហ្លួងវិចិត្តវោហារជាម្ចាស់ថ្មី បានដឹងថាអាម៉ូតត្រូវទោស
ហ្លួងដូច្នោះ ក៏ខានយកប្រាក់ទៅបង់ឲ្យលោកព្រះចំរើនពលទិ
ព្យៗ ក៏ខានបានប្រាក់១០០បាទអំពីតួអាម៉ូត ព្រះចំរើនពលទិ
ព្យកើតក្តៅក្រហាយស្តាយប្រាក់១០០បាទ ដែលគេយកមក....

....ឲ្យដល់ផ្ទះហើយខ្លួនមិនទទួលព្រោះមិនចំថ្ងៃចន្ទ ដែលខ្លួនប្រកាន់តាមតម្រាសៃយ៍នោះឯង ម្ល៉ោះហើយព្រះចំរើនពលទិព្យតាំងជេរប្រទេចក្បួនចាស់បុរាណនោះជាអនេកបរិយាយ ៗ រឿងនេះឯងស្តាប់មើលចុះ អ្នកកាន់តម្រាសៃយ៍ដល់ក្តីឆោតខូចប្រាក់១០០ បាទសៀម ដូចលោកព្រះចំរើនទិព្យ ជាបែបអ្នករើសថ្ងៃល្អយាមល្អ ត្រឡប់ទៅជាខុសវិញ ឯអ្នកហ្លួងវិចិត្តវោហារម្ចាស់ថ្មីយកប្រាក់ចេញទៅលោះអាម៉ូត ហើយប្រាក់នុ៎ះមិនត្រូវបង់ក៏មិនខាតខូចទៅបាន ទុកថាជាប្រាក់គេត្រជាក់មែនបានជាបណ្តាលចិត្តលោកព្រះចំរើនពលទិព្យមិនឲ្យទទួលយកគួរឯងស្តាប់យកទុកជាគតិលោកហោង ៗ

សំដែងមកក្នុងវិធីមនុស្សឆោតល្ងង់វង្វេងដោយព្រាសចាក
សតិបញ្ញាចប់ដោយសង្ខេបតែប៉ុណ្ណេះ ។

គ្រានេះនឹងសំដែងគតិវាយ ហៅថាបកិណ្ណកគតិទៅ

កូនសិស្សតបគ្រូវិញថា សូមទានតម្រាមនុស្សឆោតខ្លៅនេះលោកគ្រូបានអធិប្បាយបរិយាយនារូបបុគ្គលប្រៀបជាឧទាហរណ៍មកសំដែងនេះ ខ្ញុំព្រះករុណាស្តាប់បានហើយ តែតអំពីនេះសូមឲ្យលោកគ្រូសំដែងរឿងប្រៀបជានិទានៗដល់ចប់



និទានមួយៗលោកគ្រូកុំចាំបាច់អធិប្បាយ ប្រាយប្រៀបទៀតឡើយទុកឱកាសឲ្យខ្ញុំព្រះករុណានឹងប្រាយប្រៀបធៀបដោយបញ្ញាខ្លួនខ្ញុំព្រះករុណាវិញ គ្រូទទួលពាក្យនាំឧទាហរណ៍ជាបកិណ្ណកនិទានតទៅ ៗ

# បកិណ្ណកគតិនឹងនិទានពីសត្វរៃកម្ជិល ១

និទាននេះមានដំណាលក្នុងក្បួនបារាំងសែស

មានសត្វរៃមួយជាសត្វខ្ជិល ដល់រដូវកាលខែពិសាខជេស្ឋអាសាធ ជាវស្សានរដូវក៏ហើរច្រៀងលេងតាមអំពើចិត្តខ្លួនពុំគួរខ្វល់ខ្វាយនឹងរកស្បៀងអាហារទុកដាក់ខ្លួន ៗ មានសត្វស្រមោចមួយពួកជាសត្វឧស្សាហ៍ពាំនាំស្រូវអង្ករទុកដាក់ក្នុងសំបុកខ្លួន គិតក្រែងក្តីក្រទៅមុខ ៗ

លុះដល់រដូវភ្លៀងឱរដោកជាំមក សត្វរៃនោះរកអាហារបរិភោគគ្មាន កើតក្តីឃ្លានចំណីក្រៃពេក ទើបហើរទៅខ្ចីអង្ករស្រមោចថា សំឡាញ់អើយសំឡាញ់ខ្លួនអញនេះពុំមានអ្វីអាស្រ័យឡើយ ព្រោះខែនេះភ្លៀងឱរដោកជាំណាស់ នឹងចេញស្វែងរកអាហារពុំបាន យើងមកនេះប្រាថ្នានឹងសូមខ្ចីអង្ករសំឡាញ់អាស្រ័យសិន ទំរាំដល់ខែប្រាំងរាំងរីះកាលណា....

នឹងរកសងសំឡាញ់ឯងវិញ ចូរសំឡាញ់មេត្តាអាណិតជួយយើង ឲ្យផុតអំពីក្តីក្រម្តងនេះចុះ សំឡាញ់ៗ

ឯស្រមោចកាលបានឮរៃស្រដីអង្វរសូមខ្ចីស្បៀងដូច្នោះ ក៏តបសួរថា អើរៃ, កាលអំពីដើមឆ្នាំខែប្រាំងរាំងរឹះនោះ តើហេតុម្តេចអ្នកឯង មិនស្វែងរកអាហារទុកដាក់សម្រាប់ខ្លួន អ្នកឯងមានរវល់កង្វល់ដោយការអ្វី?ៗ

រៃតបថា សំឡាញ់អើយ!យើងនេះពុំមានកិច្ចការអ្វីទេ រវល់តែនឹងហើរទំដោយឈើព្រៃ ស្រែកច្រៀងលេងតាមអំពើចិត្តប៉ុណ្ណោះឯង បានជាពុំបានរកស្បៀងទុកនោះៗ ស្រមោចថា អើ, ពីដើមអ្នកឯងធ្លាប់ច្រៀងយ៉ាងណា ឥឡូវនេះចូរអ្នកឯងរកទំនុកច្រៀងលេងទៅទៀតទៅ វិស័យអ្នកលេងច្រៀងរាំហើយ ត្រូវតែយើងច្រៀងរាំទៅកុំឈប់ ល្បែងច្រៀងរាំនេះ ជាប្រយោជន៍ចិញ្ចឹមជីវិតរបស់អ្នកហើយអញ្ជើញច្រៀងទៅទៀតមើល ខ្ញុំឯងនឹងស្តាប់ផងៗ

ឯរៃក៏ឆ្លើយថា ឱសំឡាញ់អើយ គ្នាអត់បាយស្ទើរតែដាច់ពោះស្លាប់ហើយ តើនឹងទៅច្រៀងរាំឯណាក៏បាន ចូរសំឡាញ់បែងចែកអង្ករ ឲ្យខ្ញុំបានអាស្រ័យខ្លះទៅអេះៗ



ស្រមោចតបថា អង្ករស្រូវរបស់យើងក៏មានខ្លះដែរ តែយើងទុកល្មមតែកូនចៅញាតិផៅរបស់យើងជាជាតិដូចគ្នា នឹងបានមានច្រើនអាចផ្សាយដល់អ្នកឯងផងនេះពុំបានទេ អ្នកឯងទៅរកខ្ចីគេឯងទៀតទៅៗ

ឯរៃបានឮស្រមោចពោលកាត់ដូច្នោះ ក៏ទាល់បញ្ញា ទើបហើរចេញចាកទីនោះឆ្ពោះទៅកាន់លំនៅនៃអាត្មា បានក្តីវេទនាដោយអត់អាហាររកបានដោយកម្រ ខំត្រដរអត់ឃ្លានតាមនិស្ស័យទៅហោងៗ

សិស្សតបថា សូមទាននិទានរឿងនេះ បានដល់មនុស្សខ្ជិលប្រកបការរកស៊ីនឹងគេ គឺដល់រដូវកាលគេធ្វើស្រែចំការ ខ្លួនមិនធ្វើនឹងគេក៏ផុតកាលរដូវនោះទៅ ម្ល៉ោះហើយក្តីក្រ ក្តីលំបាក ក៏កើតមានដល់មនុស្សនោះឯង ព្រោះអំណាចល្បែងលេងមិនគិតរកស៊ីធ្វើការ នឹងទៅរកខ្ចីបុលគេស៊ី នរណាឡើយនឹងឲ្យបាន គេក៏បំនុងរូបគេដែរ ខ្លួនក៏តោងទ្រាំវេទនាទៅតាមយថាកម្ម ដូចយ៉ាងសត្វរៃរកខ្ចីអង្ករស្រមោចៗពុំបានឲ្យខ្ចីដូច្នោះហោងៗ

ចប់តម្រាខ្ជិលទី១ៗ

# និទានពីក្អែកគោកត្រាប់តាមក្អែកទឹក

មានក្អែកគោក មួយអាស្រ័យនៅក្នុងដងព្រៃមួយអន្លើ ដោយក្អែកមេជាភរិយាថ្ងៃមួយចៅបក្សាលានាងភរិយាចេញទៅរកអាហារ បរិភោគតាមដោយមាត់បឹង លុះទៅដល់បឹង១ បានឃើញនូវហ្វូងក្អែកទឹកនឹងស្មោញទាំងឡាយ ហែលមុជចាប់ត្រីបរិភោគតាមដោយសភាពដូច្នោះ ក្អែកគោកនោះគិតថា ក្អែកទឹកអស់នេះ គេក៏ជាជាតិបក្សីដូចជាអញដែរ ហេតុអ្វីក៏គេមុជចាប់ត្រីអាស្រ័យបាន អញសោតជាក្អែកដូចគេដែរ គួរខ្មាសគេណាស់ បើដូច្នេះគួរតែចុះមុជចាប់ត្រីនឹងគេអាស្រ័យ កុំឲ្យអាពួកក្អែកទឹកនោះមើលងាយបាន គិតហើយ ក្អែកគោកក៏សម្លបស្លាប ចុះមុជទឹកធ្វើអាការដូចក្អែកទឹក ខំប្រឹងមុជទឹកទៅប៉ះសារាយណែនណាន់ សារាយនោះក៏ព័ន្ធក្អែក ស្រោបកាយជិតជុំរុំព័ទ្ធប្រាណ ក្អែករើខ្លួនពុំបាន ក៏ឈ្លក់ទឹកដល់នូវមរណកាលកណ្ដាលគង្គាក្នុងគ្រានោះហោង ។

រឿងនិទាននេះ មានសេចក្ដីពិស្ដារនៅក្នុងកាកជាតកឯណោះ ឯងស្ដាប់មើលចុះ រឿងក្អែកគោកនេះតើឯងដាក់ទុកជាគតិដូច



មានឧទាហរណ៍យ៉ាងណាចូរថាទៅមើល ។

កូនសិស្សអធិប្បាយថា ជាតិក្អែកទឹកជាសត្វធ្លាប់ហែលធ្លាប់មុជទឹក តាមសន្ដានវា អាចដឹងកាលដឹងការស្វែងរកអាហារខាងជើងទឹក ប្រព្រឹត្តទៅបានឥតទាស់ឥតទាល់ តាមភាពធម្មតាវាជាសត្វមុជទឹកទើបវារកស៊ីតាមជើងទឹកឥតក្ដីអន្ដរាយ ក៏ឯក្អែកគោកនោះជាសត្វធ្លាប់រកស៊ីតាមជើងគោក តាមភាពធម្មតាវាជាសត្វគោក ដល់ខ្លួនទៅរកស៊ីខាងជើងទឹកឯណាក៏បាន ព្រោះខ្លួនមិនធ្លាប់ នេះប្រៀបដូចមនុស្សយើងដែលកើតក្នុងវង្សអ្នកស្រែអ្នកចំការ ធ្លាប់ស្ទាត់ក្នុងការងារខាងជើងគោក ហើយដល់ខ្លួនពុំចេះអក្សរពុំចេះលេខពុំចេះដឹងក្នុងក្បួនដើរទូកថ្លៃ ទូកប៉ុកចាយ កើតនឿយណាយចោលការស្រែចំការដែលខ្លួនធ្លាប់ប្រព្រឹត្តនោះបង់ ទៅប្រកបការផ្លូវជួញប្រែ ដែលខ្លួនមិនធ្លាប់ប្រព្រឹត្តនោះវិញ ការអស់នោះឯណាឡើយនឹងសំរេចបានព្រោះខ្លួនមិនធ្លាប់ ។

តែខំប្រព្រឹត្តទៅក៏គង់ជាប់សារាយដូចក្អែកគោកនោះឯង គួរគិតមើលទៅទៀតចុះ ។

ចប់តម្រារកស៊ីខុសទី ២

## និទានពីសត្វចតុប្បាទ៣ ចចក១ ស្វាន១ ឆ្កែព្រៃ១

មានសត្វចតុប្បាទ៣ តួគឺ ចចក១ ស្វាន១ ឆ្កែព្រៃ១។ ថ្ងៃ១ សត្វទាំង៣ដើរទៅជាមួយគ្នា គ្រាកាលនោះមានសត្វសីង្ហតោ១ នៅដើមផ្លូវ បានឃើញសត្វទាំង៣មកដល់សំណាក់នៃខ្លួនទើបហៅទៅថា ហៃចៅទាំង៣ទៅណាមកណា ចូរចូលមកនេះសិន។

ឯសត្វទាំង៣បានឮសីង្ហតោ ហៅចូលដូច្នោះក៏ខ្លាចពុំហ៊ានប្រកែក ទើបនាំគ្នាចូលទៅកាន់សំណាក់នៃសីង្ហតោ ដល់ហើយក៏ឱនកាយគំនាប់សីង្ហតោតាមធម្មតាខ្លួនជាសត្វទាប ទើបសីង្ហតោសួរទៅថា "អើអ្នកឯងរកស៊ីចិញ្ចឹមជីវិតសព្វថ្ងៃនោះ តើជាបានប្រកបដោយអាហារបរិបូរណ៍ឬអត្តខាត់ណាស់ទៅ?"។

ឯសត្វទាំង៣ក៏ឆ្លើយថា "សូមទានយើងខ្ញុំរកទទួលទានចិញ្ចឹមជីវិតសព្វថ្ងៃនេះ បានដោយក្រចួនណាចាប់សត្វជាអាហារបានក៏បានបរិភោគឆ្អែតទៅចួនណារកពុំបានក៏អត់ទៅ ក្តីចិញ្ចឹមជីវិតយើងខ្ញុំនេះពុំមានកំណត់មានអត់ខ្លះឆ្អែតខ្លះតាមកាលម្តងៗ"។ សីង្ហតោក៏និយាយថា "អ្នកឯងរកស៊ីដោយភាពលំពាំងខ្លួនឯងម្នាក់ៗយ៉ាងនេះ បានជារកអាហារបានដោយក្រ បើប្រសិនជាអ្នកឯងចូលហ៊ុននឹងយើង គឺរកស៊ីកុំប៉ាញ្ញីចូលគ្នាជាហ៊ុនមួយ អ្នកឯងទាំង



៣ ទៅលើកសត្វ ដេញសត្វកៀងវាឲ្យវាមកតម្រង់មុខយើងៗជាសត្វមានអំណាចអាចចាប់ម្រឹគនោះបាន ហើយយើងបែងចែកជាភាគ៤ បានដល់គ្នាទាំង៤ អាស្រ័យយ៉ាងនេះ យល់ជាងាយសប្បាយក្នុងការរកស៊ីចិញ្ចឹមជីវិតនោះ"។ ឯសត្វទាំង៣បានឮពាក្យសីង្ហតោបបួលឲ្យចូលហ៊ុនដូច្នោះ ក៏ត្រេកអរគាប់ចិត្តទើបតបទៅថា "សូមទានបើព្រះតេជព្រះគុណប្រោសឲ្យយើងខ្ញុំចូលហ៊ុនផងនោះ ជាការងាយសប្បាយក្នុងផ្លូវរកទទួលទានពិតមែន បើដូច្នេះ អញ្ជើញព្រះតេជព្រះគុណនៅចាំទីត្រង់នេះចុះ យើងខ្ញុំ៣ តួនឹងទៅដេញម្រឹគកៀងវាឲ្យវាបោលទត់មក ត្រង់មុខព្រះតេជព្រះគុណនៅពីនេះ" ជាហើយសត្វទាំង៣ក៏នាំគ្នាលាសិង្ហតោចេញទៅដល់ព្រៃ១ ក៏បានឃើញមេក្តាន់១ កំពុងស៊ីស្មៅ ទើបនាំគ្នាដេញកៀងពីខាងក្រោយ មេក្តាន់នោះក៏ភិតភ័យ លផ្លោះទៅត្រង់ទីដែលសម្ងំនៅចាំនោះឯង ឯសត្វទាំង៣ ក៏ស្រែកប្រាប់ទៅសិង្ហតោបានឮដូច្នោះ ក៏ក្រាបចាំនៅលុះមេក្តាន់មកដល់ជិត ក៏ស្ទុះទៅចាប់បានហើយ ប្រហារមេក្តាន់នោះដល់នូវមរណកាល ហើយកាត់ជាភាគ៤ដាក់នៅទី១ ទើបហៅសត្វទាំង៣ ឲ្យចូលមកយកចំណែកតាមសញ្ញា។

ឯសត្វទាំង៣មានសេចក្ដីត្រេអរ ដោយសមក្ដីប្រាថ្នា ទើបនាំគ្នាចូលទៅកាន់សំណាក់សិង្ហតោជាមេចំណែក ៗ

ឯសិង្ហតោនោះ កាលនឹងចែកសោត ក៏សួរទៅកាន់សត្វទាំង៣នោះថា "អើអ្នកទាំង៣, ធម្មតាសត្វចតុប្បាទក្នុងលោកិយនេះ តើសត្វឯណា ជាស្ដេចលើសត្វទាំងពួង? ៗ សត្វទាំង៣ក៏ជំរាបថា "សូមទានសត្វចតុប្បាទក្នុងលោកនេះ គឺបុរាណលោកសន្មតសត្វសិង្ហគឺព្រតេជព្រះគុណនេះហើយថាជាស្ដេចជាឥស្សូរកំពូលលើពួកសត្វចតុប្បាទទាំងពួង", "អើបើអ្នកឯងថាយើងនេះជាស្ដេចពិតដូច្នោះ នោះត្រូវបានភាគ១ ដាក់ទៅខាងខ្លួនហើយសួរទៀតថា "អើអ្នកទាំង៣, សត្វក្នុងលោកិយដែលមានឈ្មោះថាសិង្ហតោៗនេះ តើមានសត្វឯណាឈ្មោះស្របយ៉ាងយើងនេះខ្លះ? ៗ "សូមទានមានសត្វឯណាឈ្មោះត្រូវត្រង់នាម ព្រះតេជព្រះគុណនេះទេទាន" ៗ

"អើបើដូច្នោះយើងឈ្មោះសិង្ហតោនេះត្រូវបានភាគ១" ថាហើយក៏ទាញយកភាគ១ដាក់ទៅខាងខ្លួនហើយសួរទៅម្ដងទៀតថា "សក្ដានុភាព កំឡាំងឫទ្ធិតេជះ មានសត្វពួកណាអាចហ៊ានស្មើនឹងយើងនេះដែរហ:" ៗ "សូមទានពុំមានទេ មានតែព្រះ...



តេជព្រះគុណនេះហើយ ជាសត្វមានសក្ដានុភាពលើសលែងសត្វពួកចតុប្បាទក្នុងលោកិយនេះឯង" ៗ

"អើបើដូច្នោះ សក្ដានុភាពយើងនេះ ត្រូវបានភាគ១", ថាហើយក៏ទាញយកភាគទី៣នោះដាក់ទៅខាងខ្លួនហើយថាភាគទី៤ ដែលសល់នេះ ត្រូវបានដល់អ្នកឯងទាំង៣តួហើយ តែយើងតម្កល់ទុកនៅខាងមាត់ឬក្រញាំងជើងយើង អ្នកឯងនាំគ្នាចូលមកយកទៅអាស្រ័យចុះ ៗ

ឯសត្វទាំង៣កាលបើឮសិង្ហតោ ពោលចែកគាគមិនយុត្តិធម៌ដូច្នោះ ក៏ទោមនស្សចូតចិត្តទីទៃៗពុំបានចូលទៅយកចំណែក១ ដែលត្រូវបានខ្លួននោះឡើយ ព្រោះខ្លាចក្រញាំជើងនឹងចង្កូមសិង្ហតោនោះទើបនាំគ្នាក្រោកដើរ ចេញទៅកាន់លំនៅនៃអាត្មាទីទៃៗ បានសេចក្ដីក្ដៅចិត្ត ដោយបង់កំឡាំង បង់ព្យាយាមដែលខ្លួនទៅដេញសត្វមកឲ្យគេ បានហើយពុំបានចំណែកនោះឯង ៗ រឿននិទាននេះ ឯងស្ដាប់យកជាគតិដូចម្ដេច ចូរប្រៀបប្រាយទៅមើល ៗ

កូនសិស្សតបថា រឿងនិទាននេះ បានសេចក្ដីប្រៀបដូចមនុស្សអ្នកក្រីក្រលំបាកគ្មានដើមទុន ហើយទៅចូលរកស៊ីធ្វើ

ការចូលហ៊ុន នឹងលោកអ្នកមានទ្រព្យសម្បត្តិ មានយសស័ក្តិជាធំ ជាមនុស្សអធម៌ ឥតក្តីអៀនខ្មាសបានខ្លាចបាប ប្រព្រឹត្តយកតែប្រយោជន៍ឯង មិនអាណិតដល់គ្នាជាអ្នកតូចទាបនោះឡើយ សំដែងយកអំណាច មកកោងសង្កត់អ្នកតូចដូចសត្វសិង្ហតោកោងសង្កត់សត្វ៣ តួនោះឯង ៕

អ្នកតូចណាទៅរកស៊ីជាមួយនឹងអ្នកធំជាងមនុស្សអធម៌យ៉ាងសត្វសិង្ហតោនោះហើយ ក៏នឹងបានក្តីក្តៅចិត្តជាខាងក្រោយ ដូចសត្វស្លានចចកឆ្កែព្រៃនោះឯងមិនលែងឡើយ ៕

សិង្ហអើយសិង្ហតោ ជាមហាលោភា ឥតក្តីការុណ្យ
លោភយកតែឯង មិនបែងភាគហ៊ុន អាងខ្លួនមានបុណ្យ
រំលោភបំពាន ៕

អ្នកទាបឥតទុន យកខ្លួនចូលហ៊ុន ផងនឹងអ្នកមាន
ខំស៊ូឥតត្រុក ខំរុកខំរាន ដល់បានគេគ្មាន ចែកហ៊ុនឡើយណា ៕
សិង្ហតោចែកបែង គេមួយបីឯង នៅក្លែងឥច្ឆា ឲ្យហើយតែទុក
នៅមុខអាត្មា សត្វណានឹងក្លា ចូលយកភាគបាន ៕

ចប់តម្រារកស៊ីខុសទី ៣



# និទានពីសត្វកណ្តុរ២ ជាសម្លាញ់គ្នា

និទាននេះមានតំណាលក្នុងក្បួនបារាំងសែស

មានសត្វកណ្តុរ២តួជាសំឡាញ់គ្នាកណ្តុរ១នៅក្នុងផ្ទះកណ្តុរ១នៅព្រៃ ៗ ថ្ងៃមួយកណ្តុរព្រៃបបួលកណ្តុរផ្ទះជាការសប្បាយតាមភាសាជាមិត្រនឹងគ្នា កាលដែលកំពុងបរិភោគចំណីនោះ បានឮសូរមនុស្សគេគោះទ្វារ គោះបង្គួចលាន់ម៉ុងម៉ាំង ឯងកណ្តុរទាំងពីរក៏កើតក្តីតក់ស្លុតភិតភ័យ មើលឆ្វេងមើលស្តាំហើយសំងំស៊ីទៅទៀត លុះស៊ីទៅ ក៏ឮសព្ទសន្ធឹកជើងមនុស្សដើរចូលមក កណ្តុរទាំងពីរក៏រឹងតែភិតភ័យឡើងទៀត រកតែផ្លូវនឹងគេចរត់ ការដែលអាស្រ័យស៊ីល្បៀងនោះក៏ពុំមានឱជារសពីសាឡើយ ព្រោះក្តីភ័យខ្លាចក្រែងមនុស្សឬសត្វឆ្មាវាយាយីម្ល៉ោះហើយក៏ស៊ីបន្តិចបន្តួចបន្ទាន់ពេល រត់ទៅកាន់លំនៅនៃអាត្មាទីទៃ ៗ ថ្ងៃក្រោយ កណ្តុរព្រៃបបួលកណ្តុរផ្ទះទៅស៊ីល្បៀងឯទីវាលស្រែព្រៃវិញ ឯគ្រឿងម្ហូបចំណីរបស់កណ្តុរព្រៃនោះពុំសូវល្អ ព្រោះជាជាតិអ្នកថោកទាប ការដែលបរិភោគនោះពុំមានមនុស្ស ឬសត្វណាដើរទៅជិតខាង នាំឲ្យភ្ញាក់ផ្អើលឡើយ កណ្តុរទាំងពីរស៊ីល្បៀងដោយសប្បាយ ដរាប

ដល់ផ្អែតស្កប់ស្កល់ទៀងខ្លួន ៗ លុះរួចការស៊ីលៀងហើយ កណ្ដុរផ្ទះនិយាយចំអកត្មះតិះដៀលថា "ម្ហូបចំណីរបស់មិត្រឯងនេះអន់ទន់ទាបភាពអ្នកព្រៃ ដោយក្ដីពុំចេះចាត់ចែងឲ្យល្អដូចស្រុកឡើយ ស៊ូម្ហូបចំណីខ្ញុំឯងនេះមិនបានទេ ៗ

ឯកណ្ដុរព្រៃក៏តបថា "មែនហើយមិត្រឯងថានោះក្នុងថ្ងៃមុនខ្ញុំបានទៅទទួលទានភោជនាហាររបស់មិត្រឯង ឯម្ហូបចំណីមិត្រសុទ្ធសឹងតែល្អៗ តែលេបទៅ ស្ទើរតែស្ទះបំពង់កស្លាប់ជាម្ដង ស៊ីទាំងភ័យទាំងភិតបាត់រសឆ្ងាញ់ពីសា ក្នុងការលៀងនោះ ឯម្ហូបចំណីរបស់ខ្ញុំអន់ទន់ទាបពិត តែបរិភោគទៅឥតក្ដីតក់ស្លុតភ័យភិត គិតទៅយល់ថាវិសេសជាងចំណីល្អចំណីខ្ពស់ ព្រោះឥតមានក្ដីតក់ស្លុតជាអារម្មណ៍នាំឲ្យស៊ីបាយមិនបាននោះឯង ឬមិត្រឯងយល់ថាចំណីនវណាវិសេសលើសចំណីនវណា" ៗ ឯកណ្ដុរផ្ទះឮដូច្នោះក៏ពុំអាចតបតថាអ្វីទៅទៀតឡើយ ហើយក៏លាកណ្ដុរព្រៃវិលទៅកាន់លំនៅនៃអាត្មាវិញហោង ៗ

រឿងនិទាននេះ បានគតិយ៉ាងណា ចូរឯងថាទៅមើល ៗ

កូនសិស្សឆ្លើយថា រឿងនេះបានគតិដូចមនុស្សបរិភោគអាហារ ដែលកើតឡើង ដោយផ្លូវសម្មាអាជីវៈនិងផ្លូវមិច្ឆាអាជីវៈ



គឺថាបុគ្គលណាស្វែងរកស៊ីដោយការខុសគន្លងធម៌ មានលួចប្លន់ឆក់ហកជាដើម ហើយបានវត្ថុនោះមក កាលនឹងបរិភោគ ក៏មានវិប្បដិសារីរឭកឃើញនូវអំពើ ដែលខ្លួនប្រព្រឹត្តអាក្រក់នោះក៏កើតក្ដីក្ដៅក្រហាយចិត្តភិតស្លុតឡើង វត្ថុនោះទោះជាល្អជាល្អជាប្រពៃយ៉ាងណា ក៏ទៅជាឥតឱជារស ដូចគ្នានឹងវត្ថុរបស់កណ្ដុរផ្ទះ ដែលលួចគេស៊ីនោះឯង ឯវត្ថុរបស់កណ្ដុរព្រៃ ជាវត្ថុពុំល្អ តែបរិភោគទៅឥតក្ដីក្ដៅក្រហាយតក់ស្លុតនឹងអារម្មណ៍អ្វី ព្រោះវត្ថុនោះកើតដោយផ្លូវសម្មាអាជីវៈ បានមកដោយធម៌មែន បុគ្គលណាស្វែងរកស៊ីចិញ្ចឹមជីវិតដោយប្រពៃ លះក្ដីកោងឆឬលួចប្លន់គេ ឬលះបង់ផ្លូវជំនួញទាំង៨ ប្រការមាន លក់គ្រឿងប្រហារជាដើម វត្ថុដែលបានមកដោយធម៌ មានប្រកបការធ្វើស្រែចំការជាដើម ហើយកាលនឹងបរិភោគ ក៏ឥតមានក្ដីវិប្បដិសារី ភិតភ័យដោយអារម្មណ៍ឯណាមួយឡើយ ម្ល៉ោះហើយសេចក្ដីសុខកាយសប្បាយចិត្តក៏មានឡើង ទោះវត្ថុនោះ ពុំឆ្ងាញ់ពីសាក្ដីក៏កើតមានរសពីសាឡើង ដូចវត្ថុរបស់កណ្ដុរព្រៃនោះឯង ៗ

ចប់តម្រាសម្មាអាជីវៈ មិនច្ឆាអាជីវៈនិងជាគតិទ៤ ៗ

# និទានពីសត្វចចកមួយលោភអាហារ

មានសត្វចចក១ ដើរស្វែងរកអាហារបរិភោគលុះដើរដល់ទីព្រៃ១បានឃើញខ្មោចដំរីសារ១ ដួលស្លាប់ហើមប៉ោងនៅខាងព្រៃដង្គុំ ទើបចចកកើតលោភចេតនាគិតថា លាភោបវមលាភអើយ ថ្ងៃនេះអញបានចំណីយ៉ាងសន្ធឹកអាស្រ័យ ៤ ទៅ ៥ ថ្ងៃក៏ពុំអស់ បើដូច្នេះគួរអញកាត់វច្ចមគ្គ(ទ្វារធំ) ស៊ីរូងចូលទៅពោះដំរីអាស្រ័យគ្រឿងក្នុងអស់កាលណា សឹមអញចេញមកអាស្រ័យសាច់ខាងក្រៅ គិតហើយចចកកាត់ទ្វារធំនៃសាកសពដំរីនោះ រូងចូលទៅក្នុងពោះដំរី ស៊ីគ្រឿងក្នុង។

ឯសាកសពដំរីនោះ កាលពេលថ្ងៃក្តៅស្វិតរីងទ្វារធំនោះក៏ទន់ចុះ ទ្វារធំនោះក៏រីកបិទជិតចូលជាមួយគ្នាទៅ។ ឯចចកនៅក្នុងពោះដំរីនោះ នឹងរកច្រកចេញមកខាងក្រៅពុំបាន ក៏តាំងថប់ដង្ហើម បាននូវសេចក្តីទុក្ខវេទនានៅក្នុងពោះដំរី ២-៣ថ្ងៃ ស្ទើរតែនឹងស្លាប់នៅក្នុងពោះដំរីនោះឯង លុះដល់ថ្ងៃក្តៅខ្លាំងសាកសពនោះរីងឡើង ទើបបានឃើញទ្វារចេញមកខាងក្រៅបាន។

រឿងនិទាននេះ កើតបានសេចក្តីប្រៀបប្រាយដូចម្តេច ឯង



ទៅមើល។

កូនសិស្សតបថា រឿងនិទានចចកនេះ បានគតិដូចមនុស្សលោភលាភកើន ហើយប្រាសចាកសតិសម្បជញ្ញៈនឹងពិចារណាមើលកលមើលការ ហៅថា ស៊ីអាហារមិនដឹងប្រមាណ ដូចបុគ្គលអ្នកស្វែងលាភ បានលាភហើយក៏រឹតតែលោភខ្លាំងឡើង ទាល់តែរកឱកាសនឹងដកខ្លួនចេញពីលាភនោះពុំបានដូចចចកនោះឯង។

ចប់តម្រារកស៊ីលោភលាភកើនប្រមាណទី ៥

# និទានពីឆ្កែស្រុក ១ មានប្រឡៀ

និទាននេះមានដំណាលក្នុងក្បួនបារាំងសែស

មានសុនខស្រុក១ បោលទៅលេងព្រៃបានឃើញឆ្កែព្រៃ១រូបស្គមឈរនៅទី១ ទើបចូលទៅធ្វើបដិសណ្ឋារសួរទទួលតាមភាសា ហើយសូមគ្នាជាមិត្រ។ ឆ្កែស្រុកសួរទៅថា "មិត្ររកស៊ីចិញ្ចឹមជីវិតសព្វថ្ងៃនេះតើញ៉ាំងបានបរិបូណ៌ឬអត្តខាត់ណាស់ទៅ?។

ឆ្កែព្រៃតបថា "សំឡាញ់អើយ! ខ្ញុំឯងនេះជាជាតិសត្វព្រៃរកស៊ីដោយកម្លាំងខ្លួនឯង ជួនណាបានបរិបូណ៌ទៅ ជួនណារកពុំ

បានក៏អត់ទៅ"។ ឯឆ្កែស្រុកក៏បបួលថា "មិត្រឯងនៅព្រៃ ឥតមានគេចិញ្ចឹមយ៉ាងនេះជាទីលំបាកពេកណាស់ បើដូច្នេះមិត្រទៅនៅនឹងនាយខ្ញុំឯស្រុក គឺនៅជាមួយនឹងខ្ញុំនេះចុះ នាយខ្ញុំឯងនោះគាត់ចិត្តល្អណាស់ គាត់ឲ្យបាយត្រីចំណីបរិភោគជាប្រក្រតី" ឆ្កែព្រៃសួរថា "កិច្ចការរបស់នាយអ្នកឯងនោះ តើប្រព្រឹត្តទៅយ៉ាងណាខ្លះ?។ ឆ្កែស្រុកជានាយខ្ញុំនោះ ពុំមានកិច្ចការអ្វីជាទម្ងន់ទេ គឺគេប្រើឲ្យដេកនៅចាំផ្ទះ១, គឺកាលណាគេទៅលេងព្រៃនោះត្រូវយើងទៅនឹងគេ មើលកាលវេលា ជួយដេញខាំសត្វម្រឹគផ្សេងៗ បាននាំមកឲ្យគេ១នែមិត្រ កិច្ចការរវល់នាយយើងនេះមានតែ២ ប្រការប៉ុណ្ណោះឯង រួចស៊ីបាយឆ្អែតដេកទៅ"។

"ឱ! ការនាយអ្នកឯងតែប៉ុណ្ណោះនោះល្មមនឹងធ្វើបានតែថារបស់អ្វីដែលព័ទ្ធអ្នកនេះហះ"។ "ឱ! នេះគេហៅប្រឡៀវណាសំឡាញ់?។ "នែសំឡាញ់ប្រឡៀវនេះគឺគេចងចំណាំថាជារបស់គេ"។ "អើ បើដូច្នោះខ្លួនអ្នកឯងមានម្ចាស់ឥស្សរៈលើក្បាលហើយ ទើបគេចងប្រឡៀវនេះដោយសំគាល់ថាជារបស់គេ ជាហើយសំឡាញ់ធម្មតាសត្វមានគេជានាយកលើក្បាលនេះ, តែក្តីខុសចិត្តគេកាលណានឹងបងព្រនង់គង់នឹងត្រូវអំបែងក្បាល ក្នុង



កាលនោះឯងពុំខានឡើយ, ហើយចុះសំឡាញ់ខ្លួនខ្ញុំនេះជាសុនខព្រៃ ឥតបីមាននរណាចានាយកលើក្បាល រកស៊ីត្រអាលតាមចិត្តឥតផ្គាប់ផ្គុនយកចិត្តឬក្រែងចិត្តនរណា ស្វែងរកអាហារដោយលំពាំងកម្លាំងខ្លួនឯង បានតិចអាស្រ័យតិច បានច្រើនអាស្រ័យច្រើនទៅ ជាការឥតនាយចៅហ្វាយតាមចិត្តសប្បាយ ចង់ដេកក៏ដេកទៅ ចង់ទៅណាមកណាក៏ទៅៗ មិនបាច់ចាំប្តឹងចាំលាគេឲ្យលំបាក, នែសម្លាញ់ធម្មតាសត្វមានគេចិញ្ចឹងនេះ មានសេចក្តីសុខកាយក៏ពិតហើយ ព្រោះនាយគេជួយការពារអន្តរាយក្នុងកាលដែលមានមកម្តងៗ តែចំណីអាហារនៅលើគេៗ ចង់ឲ្យវេលាណាក៏បានអាស្រ័យវេលានោះទៅទុកជាខ្លួនកើតឃ្លានអ្វីយ៉ាងណាក៏ដោយ គេក៏ពុំបានឲ្យក្នុងកាលដែលខុសពេលនោះឡើយ គឺគេឲ្យតែក្នុងពេលព្រឹកល្ងាចប៉ុណ្ណោះឯង គិតទៅឃើញថាអាប្រឡៀវចងកនេះជាការនាំឲ្យចង្អៀតកខ្លួនឯង ស៊ូខ្ញុំឯងកនៅទទេនេះជាជាង តាមចិត្តខ្ញុំជាជាតិឆ្កែព្រៃខ្ញុំឯងមិនចង់បានប្រឡៀវឲ្យព័ទ្ធកខ្ញុំទេ" ឆ្កែព្រៃថាដូច្នោះហើយ ក៏លាឆ្កែស្រុកទៅកាន់លំនៅអាត្មាវិញហោង។

រឿងនិទាននេះមានសេចក្តីប្រៀបជាគតិយ៉ាងណាចូរឯងប្រៀប

ទៅមើល ។

កូនសិស្សតបថា សូមទានរឿងនេះករុណាមិនតោងចាំ
ប្រែប្រាយ ឲ្យពិស្តារក៏បានព្រោះជារឿងត្រូវត្រង់បុគ្គល
មានគេនាយក នឹងបុគ្គលឥតគេនាយក ដូចឆ្កែព្រៃពោលមក
នោះហើយ នឹងពោលចំពោះតែប្រឡៅម្យ៉ាង បានខាងគ្រឿង
ឥស្សរិយយសទាំងឡាយ មានសញ្ញាបត្រ ឬមេដាយត្រាតាំងជា
ដើម បុគ្គលមានយសស័ក្តិពាក់ប្រដាប់កាយអួតគ្នា សរសើរគ្នា
ក្នុងលោកិយនេះ តែគ្រឿងអាភរណៈពោលគឺប្រឡៅនេះ ជា
គ្រឿងនាំឲ្យកំរើកចិត្ត ឲ្យស្រវឹងយសទៅផ្សេងៗ អ្នកមាន
បញ្ញាគួរត្រិះរិះពិចារណាទៅតាមគតិធម៌វិញចុះ ។

ចប់តម្រាគតិប្រឡៅទី ៦

## និទានពីមេឆ្កែកំផើម១ សម្រាលកូន

និទាននេះមានដំណាលក្នុងក្បួនបារាំងសែស

មានមេឆ្កែ១មានផ្ទះមានភូមិស្ថានជាលំនៅ ថ្ងៃ១មានឆ្កែកំផើ
ម១ ដល់កំណត់គភ៌ចាស់នឹងសម្រាលកូន ក៏ដើរស្វែងរកកន្លែង
នឹងសម្រាល លុះដើរទៅដល់ទីភូមិផ្ទះមេនោះ ក៏ចូលទៅនិយា
យថា "សំឡាញ់អើយ! ខ្លួនខ្ញុំនេះមានគភ៌ចាស់ថ្ងៃ នឹងសម្រាល



កូនក្នុងថ្ងៃនេះហើយ ចូរសំឡាញ់មេត្តា ឲ្យខ្ញុំខ្ចីផ្ទះសម្រាលកូន
បាន១ ថ្ងៃសិន" ។ ឯមេជាម្ចាស់ផ្ទះក៏ឆ្លើយថា ឱសំឡាញ់អើយ
ផ្ទះខ្ញុំនេះតូចណាស់ ចង្អៀតណាស់ នៅបានតែម្នាក់ៗ បើសំឡា
ញ់ឯងមកខ្ចីសម្រាលកូន តើឲ្យយើងទៅនៅអាស្រ័យឯណា? ។

មេកំផើមក៏អង្វរថា "សំឡាញ់អើយ ចូរមេត្តាដល់ខ្ញុំចុះ កុំថា
អ្វីឡើយ ធ្វើម្តេចការឆ្លងទន្លេនេះ ជាការក្រលំបាកណាស់ នឹង
ទៅសំរាលក្នុងទីវាលកាលឯណាបាន តោងរកទីបន្ទប់ ទីមានវត្ថុ
បិទបាំងទើបសម្រាលបាន ហេតុនេះខ្ញុំឃើញតែផ្ទះសំឡាញ់
ឯងនេះ ជាទីគួរសំរាលបាន សូមសំឡាញ់ជួយដោះទុក្ខ គឺជួយ
ចម្លងខ្ញុំឲ្យដល់ត្រើយ យកបុណ្យទៅមុខចុះខ្ញុំមិននៅយូរទេ
តែសំរាលរួចកាលណា នឹងលាចុះវិញ អញ្ជើញសំឡាញ់ឡើង
មកនៅដូចកាលមុនហោង" ។

ឯមេឆ្កែម្ចាស់ផ្ទះ ឮមេកំផើមអង្វរដូច្នោះ ក៏កើតក្តីអាណិត
ដោយជាតិជាញាតិដូចគ្នា ទើបចុះចាកគ្រឹហាហើយថា "ចូរឯងឡើ
ងទៅសម្រាលកូននៅលើផ្ទះយើងនេះចុះ" ថាហើយក៏ដើរចេ
ញទៅកាន់ទីដទៃនៅចាំទម្រាំគេសម្រាលកូនរួច ។ ឯមេកំផើម
បានឱកាសហើយ ក៏ឡើងទៅសំរាលកូននៅលើផ្ទះនោះលុះ

ស្រេចហើយមេនោះនៅអស់មួយថ្ងៃ លុះព្រឹកឡើងមេម្ចាស់
ផ្ទះក៏មកទារយកផ្ទះខ្លួន ដល់ហើយថាសំឡាញ់ឆ្លងទន្លេ រួចស្រួ
លបួលហើយហះ បើសំឡាញ់រួចកិច្ចនោះហើយ ចូរចុះចេញពី
ផ្ទះយើងចុះយើងនឹងឡើងទៅនៅវិញ យើងទ្រាំនៅដោយវាល
កាលអស់១ថ្ងៃហើយ ៗ ឯមេមានកូនក៏អង្វរថា "សំឡាញ់អើយ!
សូមអាណិតខ្ញុំសិនចុះ ត្បិតកូនខ្ញុំនេះវានៅតូចណាស់ មិនទាន់បើ
កភ្នែកផង នឹងនាំយកទៅឯណាបានបើដូច្នេះ សូមមេត្តាបង្អង់
បាន ៣ ៤ថ្ងៃចាំកូនវាបើកភ្នែក ល្មមដើរបានកាល ខ្ញុំនឹងនាំចេញ
ទៅក្នុងកាលនោះឯង ៗ

ឯមេម្ចាស់ផ្ទះ ក៏កើតចិត្តអាណិតបើកឲ្យមេមានកូននៅចាំកូន
បើកភ្នែក ៗ លុះនៅកន្លងមក ៤ ៥ថ្ងៃទៀត មេម្ចាស់ផ្ទះនោះ
ទៅទារយកផ្ទះវិញ ៗ ឯមេមានកូនក៏អង្វរទៀតថា "សំឡាញ់
អើយ! ចូរមេត្តាខ្ញុំសិនត្បិតកូនខ្ញុំនៅមិនទាន់រឹងដៃរឹងជើង នឹង
បណ្ដើរទៅបានបើដូច្នេះបង្អង់ចាំកូនខ្ញុំ វារឹងដៃរឹងជើងល្មម
បណ្ដើរបានកាលណា សឹមខ្ញុំនាំចេញទៅក្នុងកាលនោះឯង" ៗ

ឯមេម្ចាស់ផ្ទះក៏អាណិតដោយគិតឃើញថាមែនទើបបើកឲ្យ
មេនោះនៅតទៀត លុះនៅកន្លងមកបានកន្លះខែក៏ទៅទារយក



ផ្ទះម្ដងទៀត ៗ ឯមេមានកូនក៏អង្វរទៀតថា "សំឡាញ់អើយ!
ខ្ញុំនឹងបណ្ដើរកូនទៅឯណាបាន ត្បិតវានៅមិនទាន់ដុះធ្មេញដុះ
ចង្កូម ហើយមិនទាន់ចេះស៊ីបាយរឹងផង ដូច្នេះសូមមេត្តាបង្អង់
សិនចាំកូនវាដុះធ្មេញចេះស៊ីបាយកាលណា ខ្ញុំនឹងនាំចេញពីផ្ទះ
នេះក្នុងកាលនោះឯង" ៗ

ឯមេម្ចាស់ផ្ទះក៏ទទួលអង្វរហើយបោលចេញទៅរកទីឯទៀ
តអាស្រ័យនៅ លុះនៅយូរខែមក កូនឆ្កែទាំងឡាយនោះដុះ
ធ្មេញដុះចង្កូមចេះខាំពាំអ្វីៗបាន ៗ ឯមេម្ចាស់ផ្ទះក៏ទៅទារយក
ផ្ទះទៀត ៗ ឯមេមានកូននោះកើតអាងកូនជាកម្លាំង លុះឮមេ
ម្ចាស់ផ្ទះមកទារយកផ្ទះ ក៏កើតមានះកោងគំរាមតបទៅថា "ផ្ទះ
នេះមិនមែនជាផ្ទះនាងឯងទេ គឺជាផ្ទះរបស់យើងៗនឹងចុះចេញ
ចោលពុំបានទេ នាងឯងនៅឯណាបានជាមកស្ដីទារយកផ្ទះនេះ
នរណាទៅខ្ចីឬជួលពីកាលណា ៗ ឯកូនឆ្កែទាំងនោះក៏ជួយម្ដាយវា
តាំងនាំគ្នាសំញិញធ្មេញបញ្ចេញសព្ទព្រុសឡើងថា "មេកញ្ជា
ស់នេះ ហេតុអ្វីក៏មកស្ដីទារយកផ្ទះរបស់មេយើង ផ្ទះនេះយើង
កើតឡើង ឃើញតែមេនឹងយើងនេះនៅ ផ្ទះនេះជាផ្ទះយើង
ប្រាកដ មេកញ្ជាស់ឯងនៅឯណា បានជាមកចោទឆយកផ្ទះយើង

យើងមិនឲ្យទេ តែខំចូលមកឬឡើងមកលើផ្ទះយើងៗ ម្តាយនឹងកូនព្រួតគ្នាខាំមេកញ្ជាស់ឯងស្លាប់ក្នុងកាលឥឡូវនេះ, តែនមេកញ្ជាស់ ចូរចៀសចេញទៅ តែខំនៅក្នុងទីនេះយើងនឹងចោមគ្នាខាំឲ្យស្លាប់ហោង"ៗ

ឯឆ្កែម្ចាស់ផ្ទះនោះ លុះឮមេឆ្កែនឹងកូនវានាំគ្នាគំរាមយកផ្ទះខ្លួនដូច្នោះ ក៏កើតក្តីខ្លាច ព្រោះគេមានគ្នាច្រើន ពុំអាចនឹងយកផ្ទះនោះបានឡើយ កើតក្តីទោមនស្សតូចចិត្តក្រៃពេកណាស់ ទើបលះបង់ផ្ទះនោះចោល បោលទៅកាន់ទីដទៃ ផ្ទះនោះក៏បានទៅមេមានកូននោះឯងៗ

រឿងនិទាននេះ បានសេចក្តីប្រៀបជាគតិយ៉ាងណា ចូរឯងអត្ថាធិប្បាយទៅមើលៗ

កូនសិស្សតបថា និទានរឿងនេះបានដូចបុគ្គលអ្នកមានដីភូមិមានដីភូមិឬស្រែចំការ ហើយមានអ្នកក្រៅចូលមកសូមធ្វើឬអាស្រ័យ តែដល់យូរទៅអ្នកក្រៅវាមានកូនចៅធំឡើង កូនចៅនោះវាទៅរៀនវិជ្ជាបានជាថីឬនាហ្មឺនឡើងកាលណា ដីភូមិទីស្រែចំការអស់នោះ ម្ចាស់ដើមយកវិញឃើញជាពុំបាន ដូចមេឆ្កែមានកូនអាកំឡាំងកូន កំហែងកោងយកផ្ទះមេម្ចាស់នោះឯង គួរពិចារណាគិតទៅចុះៗ



**ចប់តម្រាធ្វើគុណបានទោសទី ៧**

**ចប់ភាគទី៤ តែប៉ុណ្ណោះ ។**